# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសង

**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង

**ថ្ងៃដាក់** : ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥

**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ

**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Jun-2015, 14:47
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ** អមដោយឧបសម្ព័ន្ធសម្ងាត់បំផុត៥

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

## ការដាក់បញ្ជាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ
## ១) កំណត់ហេតុស្តាប់ចម្លើយ DC-Cam ចំនួនពីរ និង ២) ឯកសារពីសំណុំរឿង០០៣ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៣-D100/9

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**

លោក Nicholas KOUMJIAN

**ចម្លងជូន:**

លោកស្រី ជា លាង

**មេធាវីប្រចាំការ:**

លោកស្រី ទូច វល្ល័ក្ស

លោក Calvin SAUNDERS

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក ពេជ អង្គ

លោកស្រី Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោក Arthur VERCKEN

លោកស្រី Anta GUISSÉ

## I. ការដាក់បង្ហាញ

១. សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") សូមដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារពាក់ព័ន្ធមួយចំនួន ដែលបានទទួលយករួចហើយនៅក្នុងសំណុំរឿង០០៣ ដែលពាក់ព័ន្ធទៅនឹងសវនាការក្នុងសំណុំរឿង០០២ ("សម្ភារៈ") ព្រមទាំងកំណត់ហេតុដែលអាចរកបានជាសាធារណៈចំនួនពីររបស់ DC-Cam។ កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់នេះសុទ្ធតែបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ព័ន្ធ ១** សម្ងាត់បំផុត។ កំណត់ហេតុរបស់ DC-Cam ទាំងពីរត្រូវបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ព័ន្ធ ២** និងបានដាក់ភ្ជាប់មកជាមួយជាឯកសារយោង។

២. សហព្រះរាជអាជ្ញា សូមអនុញ្ញាតដាក់បង្ហាញសម្ភារៈទាំងនេះ ដែលបានបញ្ចូលនៅក្នុងសំណើសុំដាក់បង្ហាញនេះ តាមរយៈសំណើសុំចំនួនបួន (សំណើទាំងបួនរួមគ្នាហៅថា "សំណើ") ដែលបានដាក់ជូនសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៤[1], ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤[2], ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥[3] និងថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥[4]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (សចសអ) បានអនុញ្ញាតឲ្យដាក់បង្ហាញតាមសំណើទាក់ទងឯកសារដែលបច្ចុប្បន្នបាននឹងកំពុងដាក់បង្ហាញនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៥ និងបានអនុញ្ញាតឲ្យដាក់បង្ហាញបន្ថែមនូវឯកសារចំនួនពីរទៀតដែលគាត់បានពិចារណាថា មិនអាចផ្តាច់ចេញពីឯកសារមួយនៃឯកសារទាំងពីរដែលបាន និងកំពុងដាក់បង្ហាញតាមសំណើនោះ[5]។ សេចក្តីសម្រេចនេះត្រូវបានចែកចាយជូនអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃចេញ។

៣. អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា កាតព្វកិច្ចដើម្បីបង្ហាញសម្ភារៈពាក់ព័ន្ធ ទោះជាដាក់បន្ទុក ឬដោះបន្ទុកក្តី គឺជាកាតព្វកិច្ចមួយដែលអង្គជំនុំជម្រះសាលាដំបូងជាប់ជំពាក់ ដូចគ្នានឹងជនជាប់ចោទដែរ ដោយហេតុថា "វាជាប្រយោជន៍ដែលនាំដល់ការស្វែងរកការពិត បើអង្គជំនុំជម្រះមានសិទ្ធិចូល

---

[1] សំណុំរឿង 003-**D100** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយនៃសំណុំរឿង ០០៣ ដែលពាក់ព័ន្ធនឹងសវនាការសំណុំរឿង០០២/០២, ៥ ឧសភា ២០១៤។

[2] សំណុំរឿង 003-**D100/2** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៣ ដែលពាក់ព័ន្ធនឹងសវនាការសំណុំរឿង០០២/០២, ១៥ ធ្នូ ២០១៤។

[3] សំណុំរឿង 003-**D100/7** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៣ ដែលពាក់ព័ន្ធនឹងសវនាការសំណុំរឿង០០២/០២, ១៦ មីនា ២០១៥។

[4] សំណុំរឿង 003-**D100/8** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង ០០៣ ដែលពាក់ព័ន្ធនឹងសវនាការសំណុំរឿង០០២/០២, ២២ មេសា ២០១៥។

[5] សំណុំរឿង 003-**D100/9** សេចក្តីសម្រេចលើសំណើសុំដាក់បង្ហាញក្នុងសំណុំរឿង០០២ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សំណើលេខ D100, D100/2, D100/6, D100/7 និង D100/8, ១៤ ឧសភា ២០១៥។

ពិនិត្យមើលឯកសារទាំងនេះ"[6]។ ជាងនេះទៀត អង្គជំនុំជម្រះនេះធ្លាប់បានសម្រេចពីមុនថា "វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចជាបន្តបន្ទាប់ទៅលើសហព្រះរាជអាជ្ញា ក្នុងការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង នូវសម្ភារៈណាមួយដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ដែលអាចជានត្តិភាពនៃពិរុទ្ធ ឬសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬអាចមានឥទ្ធិពលទៅលើភាពជឿជាក់បាននៃភ័ស្តុតាង"[7]។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំថា ដំបូងសហព្រះរាជអាជ្ញាត្រូវដាក់សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះដោយប្ដឹងពីភ័ស្តុតាងដែលខ្លួនចង់ដាក់បង្ហាញ បន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឱ្យទទួលយកឯកសារនោះ ទុកជាការអនុម័តសម្រាប់ការដាក់បង្ហាញឯកសារ[8]។

៤. អង្គជំនុំជម្រះសាលាដំបូងពីមុនធ្លាប់បានបង្គាប់ថា គ្រប់ការដាក់បង្ហាញឯកសារទាំងអស់ ពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២ គម្បីដាក់ និងជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងជាបណ្ដោះអាសន្នដោយឈរលើមូលដ្ឋានសម្ងាត់បំផុត និងថាបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ចំពោះឯកសារនោះថាតើ គម្បីដាក់ចំណាត់ថ្នាក់ឡើងវិញថា សម្ងាត់ ឬក៏អត់[9]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីកំណត់ហេតុដែលមាននៅក្នុង **ឧបសម្ព័ន្ធ ១** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត។ ដើម្បីឱ្យស៊ីសង្វាក់គ្នា សហព្រះរាជអាជ្ញា ក៏សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីឯកសារ DC-Cam ក្នុង **ឧបសម្ព័ន្ធ ២** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត ផងដែរ។

៥. សចសអ នាពេលថ្មីៗនេះបានកែប្រែការដាក់កម្រិត និងបែបបទមួយចំនួនសម្រាប់ការអនុវត្តចំពោះឯកសារដែលបានដាក់បង្ហាញពីសំណុំរឿង០០៣ និង០០៤ ក្នុងសំណុំរឿង០០២[10]។ ការអនុញ្ញាតស្ដីពីការដាក់ឯកសារ ពេលនេះត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

---

[6] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្ដល់សក្ខីកម្មក្នុងសំណុំរឿង០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។

[7] *ដដែលដូចខាងលើ,* ត្រង់ទំព័រ១។

[8] **E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងចម្លើយសាក្សីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២, ១៦ សីហា ២០១៣, កថាខណ្ឌ២។

[9] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្ដល់សក្ខីកម្មក្នុងសំណុំរឿង០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២, ត្រង់ទំព័រ១។

[10] សំណុំរឿង 004-**D193/19** ដីកាសម្រេចកែប្រែដីកាសម្រេច D193/4, D193/6, D193/8, D193/10, D193/11, D193/13, D193/15 និង D193/16 លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៅក្នុងសំណុំរឿង ០០២/០២, ១៣ មីនា ២០១៥។

ក. រាល់សម្ភារៈទាំងអស់ត្រូវចាត់ទុកថា ជាឯកសារសម្ងាត់។

ខ. ត្រូវប្តូរសម្ភារៈទៅជាសំណៅថតចម្លងអេឡិចត្រូនិច ក្នុងទម្រង់ណាមួយដែលអាចធ្វើឱ្យអក្សរបង្កប់(watermark)ដែលមិនអាចលុបបាន នៅលើទំព័រនិមួយៗនៃឯកសារទាំងអស់ដែលកំណត់បានពីបុគ្គលិកលក្ខណៈសម្រាប់ភាគីទទួលនិមួយៗ។

គ. សម្ភារៈដែលត្រូវផ្តល់ជូនមេធាវីការពារក្តីជនជាប់ចោទទាំងពីរ មេធាវីប្រចាំការរបស់ខៀវ សំផន និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសំណៅថតចម្លងអេឡិចត្រូនិចដែលមានអក្សរបង្កប់ និងកំណត់បានពីបុគ្គលិកលក្ខណៈនិមួយៗ។

ឃ. កសព ត្រូវតែបង្ហាញឯកសារក្នុងរបៀបមួយដែលភាគីនិមួយៗ អាចចូលពិនិត្យមើលបានតែតាមរយៈសំណៅថតចម្លងអេឡិចត្រូនិចដែលមានអក្សរបង្កប់ ដែលមានការកំណត់ពីបុគ្គលិកលក្ខណៈនិមួយៗរបស់ខ្លួនតែប៉ុណ្ណោះ។

ង. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់បង្ហាញសម្ភារៈដែលបានផ្តល់ជូនតាមសេចក្តីសម្រេចនេះ ឱ្យទៅតែសមាជិកនៃក្រុមការងាររបស់ពួកគាត់ដែលទទួលបានការងារជាផ្លូវការតាមវិធាន វិធាន២២(៥) និង ១២(៤)*ស្ទួនពីរ* តែប៉ុណ្ណោះ។

ច. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឱ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងនៃឯកសារដើម ទោះបីជាតាមរបៀបណាក៏ដោយ ដែលនាំឱ្យសមាជិកនៃក្រុមរបស់ខ្លួននិមួយៗដែលទទួលបានការណែនាំ ឬអនុញ្ញាតឱ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់ យកសម្ភារៈទាំងនោះ ទៅប្រើប្រាស់ក្រៅពីការប្រើប្រាស់ផ្ទៃក្នុងរបស់ខ្លួនឡើយ។

ឆ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរក្សាកំណត់ហេតុស្តីពីសំណៅដែលខ្លួនបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងសម្រាប់ប្រើប្រាស់ផ្ទៃក្នុង គឺត្រូវរក្សាទុកក្នុងរបៀបមួយដែលអាចត្រួតពិនិត្យឡើងវិញបាន។

ជ. ក្នុងករណីដែលសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង០០២/០២ សម្ភារៈនោះត្រូវបានចាត់ទុកថាជាឯកសារសម្ងាត់។

ឈ. គ្មានសម្ភារៈណាដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ ត្រូវបានផ្សព្វផ្សាយដល់សាធារណជន ទោះក្នុងទម្រង់ ឬតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយក៏ដោយ។

ញ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតណាមួយនៃសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ សមាជិករូបនោះត្រូវចាត់គ្រប់វិធានការទាំងអស់ជាបន្ទាន់ ដើម្បីរក្សាការពារសុវត្ថិភាព និងប្រគល់សំណៅសម្ភារៈឯកសារនោះ ជូន សចអ វិញ; និង

ដ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កម្រិតទាំងនេះ សមាជិករូបនោះត្រូវរាយការណ៍អំពីការរំលោភបំពាននោះជូន សចអ។

៦. ដើម្បីអនុវត្តតាមការដាក់កម្រិតទាំងនេះ សហព្រះរាជអាជ្ញានឹងធ្វើយ៉ាងណាឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី ខៀវ សំផន និងមេធាវីប្រចាំការរបស់ ខៀវ សំផន ទទួលបាននូវសម្ភារៈទាំងនេះ និងបទសម្ភាសន៍ធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ជាសំណៅអេឡិចត្រូនិច តាមរយៈ ហ្វូលឌ័រផ្ទុកឯកសាររួម ដល់គ្រប់ភាគីទាំងអស់ឲ្យបានឆាប់តាមដែលអាចធ្វើបាន។

## II. ដំណោះស្រាយដែលស្នើឡើង

៧. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យ៖

ក. អង្គជំនុំជម្រះសាលាដំបូងទទួលយក និងដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីដូចបានកំណត់អត្តសញ្ញាណក្នុង**ឧបសម្ព័ន្ធ ១**។ និង

ខ. អង្គជំនុំជម្រះសាលាដំបូងដាក់ក្នុងសំណុំរឿងលេខ០០២ នូវបទសម្ភាសន៍របស់ DC-Cam ដែលបានកំណត់អត្តសញ្ញាណក្នុងឧបសម្ព័ន្ធ២ និងដែលបានភ្ជាប់ជាឯកសារច្បាប់យោង៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |